មិនត្រូវនាំយកទៅទីណាឡើយ បើជនជាប់ចោទបានតម្កល់និមុត្តិធានា ស្របតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់នេះ ។ ប្រសិនបើជនជាប់ចោទមិនបានតម្កល់និមុត្តិធានា ឬ បើជាទំនិញជាប់អាយ័ត ទំនិញនោះត្រូវដឹកជញ្ជូនទៅកាន់ការិយាល័យគយជិតបំផុត ឬ ប្រគល់ឱ្យតតិយជនថែរក្សានៅកន្លែងឃាត់ទុក ឬ នៅកន្លែងផ្សេងទៀត ។

**មាត្រា ៧១.‒**

បុគ្គលដែលត្រូវរងនូវទោសទណ្ឌ ឬ ការឃាត់ទុកនូវទំនិញ មធ្យោបាយដឹកជញ្ជូន ឬវត្ថុផ្សេងទៀត អាចតវ៉ាជាលាយលក្ខណ៍អក្សរទៅនាយកទីចាត់ការគយ និងរដ្ឋាករក្នុងអំឡុងពេលសាមសិប ( ៣០ ) ថ្ងៃ ក្រោយបានទទួលសេចក្តីជូនដំណឹងពីទោសទណ្ឌ ឬ ការឃាត់ទុក ដោយបញ្ជាក់ពីមូលហេតុនៃការតវ៉ា និងតម្កល់និមុត្តិធានាស្របតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់នេះ ។

នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវចេញសេចក្តីសម្រេចលើការតវ៉ាក្នុងអំឡុងពេលហុកសិប ( ៦០ ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យតវ៉ា បើមិនដូច្នោះទេ ការតវ៉ានោះត្រូវបានចាត់ទុកថាបានទទួលការយល់ព្រម ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នីតិវិធីពាក់ព័ន្ធនឹងដំណើរការតវ៉ានេះ ។

## ជំពូកទី ១១

## ទោសប្បញ្ញត្តិ

**មាត្រា ៧២.‒**

បុគ្គលណាដែលនាំចេញ ឬ នាំចូល ឬ ប៉ុនប៉ងនាំចេញ ឬ ប៉ុនប៉ងនាំចូលទំនិញដោយរំលោភបំពានលើច្បាប់ ឬ បញ្ញត្តិនានា ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើស ។

បុគ្គលណាដែលប្រព្រឹត្តបទល្មើសគយ ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលដែលកំណត់ដោយរដ្ឋបាលគយ និងទោសទណ្ឌតាមផ្លូវតុលាការដែលកំណត់ ដោយតុលាការមានសមត្ថកិច្ច ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៧៣.-**

ជនណាដែលរំលោភបំពានកម្រិតទាបលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃច្បាប់នេះដោយរាប់បញ្ចូលទាំងការចុះមិនត្រឹមត្រូវ ការភ្លេច ឬ ការខកខានចុះនូវស្ទូចនាណាមួយ ដែលត្រូវរៀបរាប់ក្នុងប្រតិវេទន៍គយ និងការខកខានបំពេញការតម្រូវ និងកាតព្វកិច្ចនានាដែលមិនប៉ះពាល់ដល់ពន្ធ អាករ អាយ័តភាព ឬការកម្រិតកំណត់ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយរយពាន់(១០០.០០០) រៀល ទៅប្រាំរយពាន់ (៥០០.០០០) រៀល ប្រសិនបើអនិយ័តភាពនេះមិនត្រូវបានរងការពិន័យធ្ងន់ធ្ងរជាងនៅក្នុងច្បាប់នេះ ។

**មាត្រា ៧៤.-**

ជនណាដែលរំលោភបំពានលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃច្បាប់នេះ ដោយរាប់បញ្ចូលទាំងការរំលោភដូចមានចែងក្នុងមាត្រា ៧៣ នៃច្បាប់នេះ ដែលមានផលប៉ះពាល់ដល់ពន្ធ ឬ អាករ និងក្នុងករណីដែលទំនិញពុំជាប់អាយ័ត ឬ កម្រិតកំណត់ ត្រូវផ្តន្ទាទោសរដ្ឋបាលដោយពិន័យជាប្រាក់ស្មើនឹងមួយ (១) ដង ទៅ បី(៣) ដង នៃប្រាក់ពន្ធ និងអាករដែលបានគេចវេះ និង ត្រូវរងនូវទោសទណ្ឌតាមផ្លូវតុលាការ ដោយត្រូវរឹបអូសទំនិញ មធ្យោបាយដឹកជញ្ជូន និងវត្ថុផ្សេងទៀតដែលប្រើសម្រាប់លាក់បំបាំងទំនិញល្មើស ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ខែ ទៅមួយ (១) ឆ្នាំ ឬ ទោសណាមួយនៃទោសទាំងពីរ ។

ត្រូវបានចាត់ទុកជាប្រភេទបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ :

ក-ការខកខានរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយ ស្របតាមបញ្ញត្តិមាត្រា ១០ និងមាត្រា ១៦ នៃច្បាប់នេះ ។

ខ-ការរើទំនិញចេញពីមធ្យោបាយដឹកជញ្ជូន មុនពេលរាយការណ៍ជូនរដ្ឋបាលគយដូចមានចែងក្នុងបញ្ញត្តិមាត្រា ១២ នៃច្បាប់នេះ ។

គ-ការបើក ការហែក គាស់ ការធ្វើឱ្យរបើក ឬ រហែកកញ្ចប់ទំនិញនាំចូល ដែលមិនទាន់ទទួលបានការអនុញ្ញាតពីរដ្ឋបាលគយឱ្យយកចេញ ការធ្វើឱ្យបែកបាក់ ខូចខាតត្រា សោ ដែលបានចាក់ ឬ បិទភ្ជាប់លើទំនិញ មធ្យោបាយដឹកជញ្ជូន កន្លែងសន្និធិគយ បណ្តោះអាសន្ន ភណ្ឌាគារគយមានដែនកំណត់ ឬ កន្លែងផ្សេងទៀតដែលតម្រូវដោយច្បាប់នេះ ។

ឃ-ការយកទំនិញចេញពីកន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយ កន្លែងសន្និធិគយបណ្តោះអាសន្ន ឬ ភណ្ឌាគារគយមានដែនកំណត់ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយ ។

ង-ការខកខានដាក់ប្រតិវេទន៍គយស្របតាមបញ្ញត្តិមាត្រា ២៩ នៃច្បាប់នេះ ។

ច-ការខកខានបំពេញតាមបញ្ញត្តិមាត្រា ៣០ នៃច្បាប់នេះ ។

ឆ- ការលក់ ការផ្ទេរ ការបង្វែរ ឬ ការបោះបង់ចោលទំនិញនាំចូល ដែលបានទទួលការលើកលែងពន្ធ និងអាករផ្សេងៗ ដូចចែងក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយ ។

ជ-ការខកខានអនុវត្តតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយរដ្ឋបាលគយ ពាក់ព័ន្ធនឹងទំនិញដែលស្ថិតក្រោមរបបព្យួរពន្ធ និងអាករ ស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

ឈ-ការប្រព្រឹត្ត ការយល់ព្រម ឬ ចូលរួមក្នុងការប្រកាសដោយផ្ទាល់មាត់ ឬជាលាយលក្ខ័ណ៍អក្សរដែលនាំឱ្យមានភាពមិនត្រឹមត្រូវ ក្លែងបន្លំ ឬ បោកបញ្ឆោតដែលផ្ទុយនឹងច្បាប់នេះ ។

ញ-ការរត់ពន្ធ ឬ ការប៉ុនប៉ងរត់ពន្ធទំនិញ ។

ដ- ការកាន់កាប់ លក់ ទិញ ផ្ទេរ ឬ ទទួលដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយនូវទំនិញដែលបាននាំចូលដោយរំលោភនឹងបញ្ញត្តិនៃច្បាប់នេះ ។

ជនណាប្រព្រឹត្តបទល្មើសដូចខាងក្រោម ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ដល់ប្រាំលាន(៥.០០០.០០០)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ខែ ដល់ប្រាំមួយ (៦) ខែ ឬ ទោសណាមួយនៃទោសទាំងពីរនេះ :

ក-ការខកខានបំពេញតាមបញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៥១ មាត្រា ៥២ និងមាត្រា ៥៣ នៃច្បាប់នេះ ។

ខ-ជនណាដែលបង្កឧបសគ្គ ឬ ធ្វើឱ្យរាំងស្ទះដល់មន្ត្រីគយ តាមបញ្ញត្តិដូចមានចែងក្នុងមាត្រា ៦១ នៃច្បាប់នេះ ។

គ- អ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលមិនគោរពតាមបញ្ជារបស់មន្ត្រីគយស្របតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ក្នុងមាត្រា ៦២ នៃច្បាប់នេះ ។

ጷ



ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

43/45

**មាត្រា ៧៥.-**

ជនណាដែលរំលោភបំពានលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់នេះ ដែលពាក់ព័ន្ធនឹងទំនិញជាប់កម្រិតកំណត់ ឬ ជាប់អាយ័តដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨ នៃច្បាប់នេះ លើកលែងតែវាក្យខណ្ឌ ជ នៃកថាខណ្ឌទី ១ ក្នុងមាត្រា ៧៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសរដ្ឋបាល ដោយពិន័យជាប្រាក់រហូតដល់ បី (៣) ដង នៃតម្លៃទំនិញនិងមធ្យោបាយដឹកជញ្ជូន និងត្រូវរងទោសទណ្ឌតាមផ្លូវតុលាការ ដោយរឹបអូសទំនិញ មធ្យោ-បាយដឹកជញ្ជូន និងវត្ថុផ្សេងទៀត ដែលប្រើប្រាស់សម្រាប់លាក់បំបាំងទំនិញល្មើស ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់ ប្រាំ (៥) ឆ្នាំ ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៧៦.-**

ក្នុងករណីមិនរាងចាល បទល្មើសដូចមានចែងក្នុងច្បាប់នេះត្រូវផ្តន្ទាទោសទ្វេឡើង ទាំងទោសពិន័យរដ្ឋបាល ទាំងទោសទណ្ឌតាមផ្លូវតុលាការ ។

**មាត្រា ៧៧.-**

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួល ចំពោះបទល្មើសគយដែលមានចែងក្នុងច្បាប់នេះ ។ សិទ្ធិសម្រុះសម្រួលនេះ ប្រើប្រាស់ចំពោះតែការពិន័យជាប្រាក់តែប៉ុណ្ណោះ ។ ក្នុងករណីមិនអាចសម្រុះសម្រួលបានរដ្ឋបាលគយ ត្រូវបញ្ជូនសំណុំរឿងនេះទៅតុលាការមានសមត្ថកិច្ច ។

ការសម្រុះសម្រួលអាចធ្វើទៅបាន នៅមុនពេលមានសាលក្រមរបស់តុលាការមានសមត្ថកិច្ច ។

លក្ខខណ្ឌសម្រាប់អនុវត្តសិទ្ធិក្នុងការសម្រុះសម្រួលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង